**សេចក្តីប្រកាសព័ត៌មានរួមរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**
**អង្គការសុខភាពពិភពលោក (WHO) និងអង្គការ UNAIDS**

ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៥

**បច្ចុប្បន្នភាពអំពីការឆ្លងរាលដាលមេរោគអេដស៍នៅឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង**

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសូមជូនព័ត៌មានអំពីទំហំ និងលទ្ធផលដំបូងនៃការអង្កេតស្រាវជ្រាវ ព្រមទាំងវិធានការដែលបានអនុវត្តកន្លងមក លើការឆ្លងរាលដាលនៃមេរោគអេដស៍នៅឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង។ ទន្ទឹមនឹងនេះ ការវិភាគបែបអេពីដេមីសាស្ត្រ និងអន្តរាគមន៍ឆ្លើយតបនៅតែអនុវត្តបន្ត។ ការខិតខំប្រឹងប្រែងទាំងអស់នេះ បានដឹកនាំសំរបសំរួលដោយក្រុមស្រាវជ្រាវរបស់ក្រសួងសុខាភិបាលដែលមានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ជាសេនាធិការ ដោយធ្វើការសហការយ៉ាងស្អិតរមួតជាមួយអ្នកជំនាញជាតិ និងអន្តរជាតិរួមមាន សកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរសុខាភិបាលខេត្តបាត់ដំបង អង្គការ UNAIDS, អង្គការសុខភាពពិភពលោក (WHO), UNICEF នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក (US/CDC), USAID, KHANA FHI360 សមាគមអ្នកប្រើប្រាស់ឱសថប្រឆាំងនឹងមេរោគអេដស៍ (AUA) មូលនិធិថែទាំជំងឺអេដស៍ (AHF) អង្គការ PSK មន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម និងអង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ (BFD)។

ចាប់ពីថ្ងៃទី ០៨ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ប្រជាជនឃុំរកាចំនួន ១.៩៤០នាក់ ដែលបានស្ម័គ្រចិត្តទទួលការប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងនោះចំនួន ២១២នាក់ បានរកឃើញឆ្លងមេរោគអេដស៍ ដែលមានអ្នកភូមិរកាចំនួន ១៧៤នាក់ ស្មើនឹង៨២%។ ក្នុងចំណោមអ្នកឆ្លងមេរោគអេដស៍ចំនួន ២១២នាក់ គឺមានកុមារអាយុក្រោម ១៤ឆ្នាំ ចំនួន ៣៩នាក់ ស្មើនឹង ១៨% ប្រជាជនអាយុចន្លោះពី ១៥ឆ្នាំ ដល់ ៥៩ឆ្នាំ ចំនួន ១២៧នាក់ ស្មើនឹង ៦០% និងមនុស្សចាស់អាយុចាប់ពី ៦០ឆ្នាំឡើងទៅមានចំនួន ៤៦នាក់ស្មើនឹង ២២%។ ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ចំនួន ៧៥នាក់ ដែលបានធ្វើតេស្តរកមេរោគរលាកថ្លើមប្រភេទ សេ (HCV) មាន៣៦នាក់ ស្មើនឹង ៤៨% បានឆ្លងមេរោគ HCV នេះ។

ការអង្កេតស្រាវជ្រាវរកប្រភពនៃការឆ្លងរាលដាលមេរោគអេដស៍បានរួមបញ្ចូលការសិក្សាលើករណីឆ្លង និងមិនឆ្លងមេរោគអេដស៍។ លទ្ធផលនៃការសិក្សានេះបានបង្ហាញថា អ្នកឆ្លងមេរោគអេដស៍ដែលបានចាក់ថ្នាំ និងចាក់សេរ៉ូមមានកម្រិតខ្ពស់ជាងអ្នកមិនឆ្លងមេរោគអេដស៍។ ចំលើយរបស់ក្រុមទាំងពីរនេះបង្ហាញនូវស្ថិតិដ៏មានសារសំខាន់ក្រៃលែង។ មិនមានចំលើយខុសគ្នាគួរឲ្យកត់សំគាល់រវាងក្រុមទាំងពីរលើកត្តាប្រឈមនឹងការឆ្លងមេរោគអេដស៍ផ្សេងទៀត ដែលមានក្នុងការសិក្សានេះរួមមាន ការប្រព្រឹត្តលើការរួមភេទ និងចាក់គ្រឿងញៀន។ ការឆ្លងមេរោគអេដស៍ពីម្តាយទៅកូនពុំមែនជាកត្តាប្រឈមនោះទេ ពីព្រោះភាគច្រើននៃម្តាយរបស់កុមារមានអាយុក្រោម ១៤ឆ្នាំ ដែលបានឆ្លងមេរោគអេដស៍ពុំមានផ្ទុកមេរោគអេដស៍ទេ។

ផ្អែកលើលទ្ធផលដំបូងនៃការសិក្សាខាងលើនេះ ឯកឧត្តមវេជ្ជបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាលបានក្រើនរំលឹកដល់គ្រប់អង្គភាពសុខាភិបាល ទាំងរដ្ឋ និងឯកជន ត្រូវអនុវត្តដាច់ខាតនូវវិធីសាស្ត្រ

ក្រសួងសុខាភិបាល "ក្រសួងសុខាភិបាលធានាថាគ្រប់គ្រឹះស្ថានសុខាភិបាលទាំងអស់អនុវត្តការបង្ការជាសកល ដោយប្រើប្រាស់សំភារៈ បរិក្ខារពេទ្យដែលបានរំងាប់មេរោគត្រឹមត្រូវ ព្រមទាំងផ្ដល់ការអប់រំដើម្បីបង្កើន ការយល់ដឹងដល់ប្រជាជនទូទៅអំពីការទទួលបានសេវាព្យាបាលជំងឺដែលមានសុវត្ថិភាពខ្ពស់ និងការបង្ការ ការឆ្លងមេរោគអេដស៍។ យើងបានពង្រឹងការអនុវត្តន៍គោលនយោបាយរបស់ក្រសួងសុខាភិបាល ដោយបញ្ឈប់ អ្នកប្រកបរបររកស៊ីព្យាបាលជំងឺដែលពុំមានច្បាប់អនុញ្ញាតត្រឹមត្រូវ"។

លោកវេជ្ជបណ្ឌិត ដុង អ៊ិលអាញ់ តំណាងអង្គការសុខភាពពិភពលោកប្រចាំនៅប្រទេសកម្ពុជា បាន បញ្ជាក់ថា សារសំខាន់នៃការឆ្លើយតបដ៏ឆាប់រហ័សរបស់ក្រសួងសុខាភិបាលចំពោះបញ្ហាខាងលើគឺបានទប់ស្កាត់ នូវការឆ្លងរាលដាលមេរោគអេដស៍បន្តទៀត ស្របពេលដែលកំពុងផ្ដល់សេវាសំខាន់នានាជូនដល់សហគមន៍ ដែលបានរងផលប៉ះពាល់ "មានការចាំបាច់ក្នុងការពង្រឹងការអនុវត្តន៍ច្បាប់ចំពោះផ្នែកសុខាភិបាលឯកជន និង អ្នកពុំមានវិជ្ជាជីវៈពេទ្យត្រឹមត្រូវ ដើម្បីធានាដល់ការថែទាំ និងព្យាបាលប្រកបដោយសុវត្ថិភាព និងគុណភាពខ្ពស់"។

គ្រប់គ្រឹះស្ថានពាក់ព័ន្ធបាននឹងកំពុងខិតខំប្រឹងប្រែងផ្ដល់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងការ ទទួលខុសត្រូវខ្ពស់ជូនដល់អ្នកផ្ទុកមេរោគអេដស៍ ដោយបានផ្ដល់ការថែទាំ និងព្យាបាលបន្តជាពិសេសព្យាបាល ដោយឱសថប្រឆាំងនឹងមេរោគអេដស៍នៅមណ្ឌលសុខភាពរកា បន្ថែមលើសេវាផ្ដល់ការព្យាបាលដោយឱសថ ប្រឆាំងមេរោគអេដស៍នៅមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង។ ចាប់ពីថ្ងៃទី ២២ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ អ្នក ផ្ទុកមេរោគអេដស៍ចំនួន ១៦១នាក់ បានចុះឈ្មោះនៅសេវា Pre-ART ក្នុងនោះចំនួន ៧៨នាក់ បានទទួល ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍រួចហើយ។

លោកស្រី ម៉ារីអូឌីល អែដម៉ុង (Marie-Odile Edmond) ប្រធានអង្គការ UNAIDS មានប្រសាសន៍ថា ព្រះរាជាណាចក្រកម្ពុជាមានប្រព័ន្ធរឹងមាំក្នុងការផ្ដល់ការគាំទ្រ និងថែទាំរបស់បណ្ដាញអ្នកផ្ទុកមេរោគអេដស៍ ដែលបានគៀងគរឲ្យចូលរួមយ៉ាងសកម្មក្នុងការផ្ដល់សេវាគាំទ្រចិត្តសាស្ត្រតាមរយៈសកម្មភាពចុះមូលដ្ឋាន និង តាមក្រុមគ្រួសារនៅក្នុងភូមិរកា។ លោកស្រីបានបន្ថែមថា "យើងបន្តធ្វើការងារឲ្យកាន់តែស្អិតរមួតជាមួយគ្រប់ដៃ គូក្នុងការពង្រឹងការបង្ការការឆ្លងមេរោគអេដស៍ និងការព្យាបាល ព្រមទាំងពង្រឹងប្រព័ន្ធតាមដានដើម្បីធានាថា ការឆ្លងរាលដាលមេរោគអេដស៍នឹងពុំកើតមានឡើងទៀតទេ។"

ក្រសួងសុខាភិបាលសូមបញ្ជាក់ជាថ្មីទៀតថាសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយផ្ដល់ប្រឹក្សានិង រក្សាការសំងាត់ដែលប្រកបដោយគុណភាពខ្ពស់ត្រូវបានផ្ដល់គ្រប់អតិថិជនដោយឥតគិតថ្លៃដែលមានទីតាំងនៅ ស្ទើរគ្រប់សេវាសុខាភិបាលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលដែលមានការអនុញ្ញាតពីក្រសួងសុខាភិបាល។ ពិធីសារជាតិនៃការធ្វើតេស្តឈាមរកមេរោគអេដស៍បានចែងពីការធ្វើតេស្តតាមលំដាប់លំដោយ ដែលស្រប ជាមួយនឹងសេចក្ដីណែនាំជាសកលរបស់អង្គការសុខភាពពិភពលោក (WHO)។ ចំពោះអ្នកផ្ទុកមេរោគអេដស៍ នៅប្រទេសកម្ពុជាគឺត្រូវបានផ្ដល់ការថែទាំព្យាបាលបន្ត ជាពិសេសព្យាបាលដោយប្រើឱសថប្រឆាំងនឹងមេរោគ អេដស៍ប្រកបដោយសុវត្ថិភាព និងគុណភាពខ្ពស់ដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យបង្អែកនៅទូទាំងប្រទេស រួមទាំងខេត្តបាត់ដំបងផង។

ឯកឧត្តមវេជ្ជបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានមានប្រសាសន៍រំលឹកថា "ព្រះរាជា ណាចក្រកម្ពុជាបានទទួលជោគជ័យយ៉ាងត្រចះត្រចង់ក្នុងការកាត់បន្ថយអត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ និងមានអត្រាគ្របដណ្ដប់ខ្ពស់ក្នុងការផ្ដល់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ជូនដល់អ្នកផ្ទុកមេរោគ អេដស៍ដែលបានទទួលពានរង្វាន់ពីអង្គការសហប្រជាជាតិ ដែលមានស្នាដៃក្នុងការសំរេចទិសដៅអភិវឌ្ឍន៍

សហស្សវត្ស (MDG 6, HIV) នៅឆ្នាំ២០១០។ ជាងនេះទៀត រាជរដ្ឋាភិបាលបានខិតខំផ្តល់សេវាជាសារវន្តនៃការបង្ការថែទាំនិងព្យាបាល និងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ទាំងអស់ ដោយបញ្ចៀសនូវការរើសអើង និងម៉ាក់ងាយដល់ពួកគាត់ដើម្បីឈានទៅសំរេចបាននូវគោលដៅលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍នាដំណាច់ឆ្នាំ២០២០។

ក្រសួងសុខាភិបាលសូមអំពាវនាវដល់បណ្តាញព័ត៌មាន និងសាធារណៈជនទាំងអស់សូមគោរពសិទ្ធិរបស់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងសូមទទួលស្គាល់នូវសិទ្ធិទទួលបានការរក្សាការសំងាត់ និងផ្តល់កិត្តិយសសេចក្តីថ្លៃថ្នូរក្នុងការរស់នៅដោយបញ្ចៀសនូវការរើសអើង និងម៉ាក់ងាយដល់ពួកគាត់។

ដើម្បីទទួលបានព័ត៌មានបន្ថែមសូមទាក់ទង:

<u>មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS)</u>

- វេជ្ជ. មានឈីវុន (ប្រធាន NCHADS)
  ទូរស័ព្ទដៃលេខ: +855 16 830 241/+855 12 564 711 (ពីថ្ងៃទី 11-17 ខែ មករា ឆ្នាំ 2015 )
  E-mail: mchhivun@nchads.org
- វេជ្ជ. លី ពេញស៊ុន (អនុប្រធានNCHADS)
  ទូរស័ព្ទដៃលេខ: + 855 12 850 053
  E-mail: penhsun@nchads.org

<u>អង្គការសុខភាពពិភពលោក (WHO)</u>

- វេជ្ជ. Massami Fujita , ប្រធានក្រុម HIV
  ទូរស័ព្ទដៃលេខ: + 855 12 905 161
  E-mail: FujitaM@wpro.who.int
- លោកស្រី Joy Caminade, មន្ត្រីនាំពាក្យ
  ទូរស័ព្ទដៃលេខ: + 855 12 578 802
  E-mail: rivacaj@wpro.who.int

<u>អង្គការ UNAIDS</u>

- លោកស្រី Marie-Odile Edmond, ប្រធានអង្គការប្រចាំប្រទេសកម្ពុជា
  ទូរស័ព្ទដៃលេខ: + 855 12 990 645
  E-mail: emondm@unaids.org